# ទោសគេតូចមើលឃើញធំ ទោសឯងប៉ុនភ្នំមើលមិនឃើញ

យោ បាណមតិមាបេតិ មុសាវាទញ្ច ភាសតិ

លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ ។ល។

ជនណាបំបាត់ជីវិតសត្វ ពាក្យមិនពិតចាត់ចែងចរចា
កាន់លួចយកទ្រព្យដោយចេតនា ដល់នូវភរិយាជនដទៃ ។
ជនណាប្រកបនូវគ្រឿងញៀន សុរាអាភៀនរឿយៗ នៃ
ឫសគល់កុសលមានសព្វថ្ងៃ បច្ច័យអស់លក្ខណ៍ក្នុងបុប្បន្ន ។
ឱម្នាលបុរសដ៏ចម្រើន ចេះច្រើនប្រមាទបាបតាមទាន់
ព្រោះមិនសង្រួមលោភជិះជាន់ ត្រូវវង់ទុក្ខធ្ងន់យូរបំផុត ។
ជនណាឲ្យទានដោយសទ្ធា ដោយចិត្តជ្រះថ្លាញាណសម្បយុត្ត
ជនដែលអឹមអៀនមានពុតត្បុត ទ្រឹស្តស្នូរជូរចត់ទានបាយទឹក ។
ជននោះប្រាកដជាមិនបាន សមាធិដ្ឋានឱឡារិក
ទោះខំប្រតិបត្តិថ្ងៃយប់ព្រឹក រកនឹកអារម្មណ៍ឲ្យមូលគ្មាន ។
ជនណាផ្តាច់ផ្តិលជីករំលើង ចិត្តស្នូរជួចើងទាំងប៉ុន្មាន
ជននោះយប់ថ្ងៃក៏ធ្វើបាន សមាធិកល្យាណជាឯកអគ្គ ។
ភ្លើងស្មើដោយរាគៈមិនមាន ជំនាប់ស្មើគ្មានដោយទោសៈ
គ្មានបណ្តាញណាស្មើមោហៈ ជ្រៅជាក់មិនស្មើស្ទឹងតណ្ហា ។

ងាយឃើញទោសគេបានទាំងអស់ ប៉ុន្តែចំពោះទោសអាត្មា
មិនងាយនឹងឃើញបានយ៉ាងណា ប្របហារនូវទោសអ្នកដទៃ ។
ដូចបាចអង្កាមបញ្ច្រាស់ខ្យល់ លាក់ទោសខ្លួនផ្ទាល់អចិន្ត្រៃយ៍
ប្រើឧបាយកលដូចព្រានព្រៃ កែច្នៃបិទបាំងបន្លំកាយ ។
អ្នកដែលឃើញទោសជនដទៃ រំពៃថ្កោលទោសជនទាំងឡាយ
កិលេសចម្រើនរីកសុះសាយ ជននោះឃ្លាតឆ្ងាយពីនិព្វាន ។
មិនមានស្នាមជើងលើអាកាស សមណៈពិតណាស់ក្រៅមិនមាន
ត្រេកអរអារម្មណ៍យឺតយូរថ្កាន តថាគតបានមិនត្រេតត្រូត ។
មិនមានស្នាមជើងលើអាកាស សមណៈខាងក្រៅគ្មានប្រាកដ
មិនមានសង្ខារដែលទៀងទាត់ ព្រះពុទ្ធបរិសុទ្ធគ្មានកិលេស ៕

